**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតដែនជម្រកសត្វព្រៃឆែប-ព្រះរការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតដែនជម្រកសត្វព្រៃឆែប-ព្រះរការ មានផ្ទៃដីទំហំ៣៤៧ ៥៦៨(បីសែនបួនមុឺនប្រាំពីរពាន់ប្រាំរយហុកសិបប្រាំបី)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារនិងខេត្តស្ទឹងត្រែង ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984)ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីដែនជម្រកសត្វព្រៃឆែប-ព្រះរការខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ១៩០ ០២៧ (មួយសែនប្រាំបួនមុឺនម្ភៃប្រាំពីរ)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃឆែប ផ្ទៃដីទំហំ៩០ ៣៦១(ប្រាំបួនមុឺនបីរយហុកសិបមួយ)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃព្រះរការ និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះឧត្តរ ដែលមានផ្ទៃដីទំហំ៦៧ ១៨០(ប្រាំមួយមុឺនប្រាំពីរពាន់មួយរយប៉ែតសិប)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖
- ធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃនិងប្រព័ន្ធអេកូឡូស៊ី ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ រុក្ខជាតិ និងជីវៈចម្រុះ
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសនិទានភាពនិងនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣.-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃឆែប-ព្រះរការ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តព្រះវិហារ និងរដ្ឋបាលខេត្តស្ទឹងត្រែង ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤.-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីបង្កើតដែនជម្រកសត្វព្រៃឆែប អនុក្រឹត្យស្តីពីបង្កើតដែនជម្រកសត្វព្រៃព្រះរការ និងអនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃព្រះរការ អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃធែប អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


1:450,000
0 5 10 20 km
Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984
Google Earth

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ១៧៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣
ចំណុចនិយាមការនៃផែនទីដែនជម្រកសត្វព្រៃឆែប-ព្រះរការ

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 577522 | 1553073 | 34 | 555576 | 1531583 | 67 | 509670 | 1556925 |
| 2 | 581460 | 1553186 | 35 | 555505 | 1535067 | 68 | 512350 | 1557090 |
| 3 | 584785 | 1551571 | 36 | 552513 | 1535943 | 69 | 514559 | 1559245 |
| 4 | 588213 | 1546953 | 37 | 550496 | 1536647 | 70 | 512112 | 1560031 |
| 5 | 591325 | 1545373 | 38 | 547646 | 1537687 | 71 | 510305 | 1560792 |
| 6 | 593166 | 1543403 | 39 | 545051 | 1537600 | 72 | 508215 | 1561473 |
| 7 | 596749 | 1540500 | 40 | 542447 | 1536454 | 73 | 506742 | 1562715 |
| 8 | 593212 | 1540398 | 41 | 539719 | 1534632 | 74 | 504967 | 1564049 |
| 9 | 593287 | 1535838 | 42 | 539796 | 1531855 | 75 | 503533 | 1565054 |
| 10 | 593383 | 1531831 | 43 | 539893 | 1528642 | 76 | 502062 | 1565858 |
| 11 | 594595 | 1528777 | 44 | 540715 | 1527299 | 77 | 499581 | 1566548 |
| 12 | 592357 | 1525631 | 45 | 537806 | 1527292 | 78 | 497198 | 1566087 |
| 13 | 588677 | 1526298 | 46 | 534572 | 1527289 | 79 | 495997 | 1566943 |
| 14 | 585832 | 1526652 | 47 | 531619 | 1527287 | 80 | 495442 | 1569452 |
| 15 | 583754 | 1525433 | 48 | 533281 | 1528907 | 81 | 495313 | 1571224 |
| 16 | 582546 | 1523049 | 49 | 531647 | 1530486 | 82 | 495962 | 1573014 |
| 17 | 578933 | 1523942 | 50 | 525505 | 1530172 | 83 | 496254 | 1574689 |
| 18 | 573931 | 1523796 | 51 | 519902 | 1529820 | 84 | 494103 | 1576123 |
| 19 | 574943 | 1525227 | 52 | 516015 | 1529198 | 85 | 491899 | 1573817 |
| 20 | 575414 | 1527382 | 53 | 511091 | 1528955 | 86 | 489862 | 1576898 |
| 21 | 572800 | 1527084 | 54 | 508597 | 1531179 | 87 | 488976 | 1579805 |
| 22 | 569482 | 1526941 | 55 | 505970 | 1532488 | 88 | 487154 | 1582216 |
| 23 | 565911 | 1526068 | 56 | 503651 | 1535211 | 89 | 483469 | 1582268 |
| 24 | 566690 | 1529003 | 57 | 500250 | 1534282 | 90 | 479638 | 1582322 |
| 25 | 567490 | 1532000 | 58 | 496976 | 1539198 | 91 | 479478 | 1588927 |
| 26 | 565309 | 1531260 | 59 | 496721 | 1542547 | 92 | 475599 | 1588945 |
| 27 | 563219 | 1530611 | 60 | 498256 | 1545683 | 93 | 475453 | 1591241 |
| 28 | 561194 | 1529753 | 61 | 498643 | 1548657 | 94 | 477110 | 1592333 |
| 29 | 560322 | 1531336 | 62 | 498088 | 1553029 | 95 | 473544 | 1592157 |
| 30 | 558900 | 1529686 | 63 | 503154 | 1553733 | 96 | 476649 | 1594760 |
| 31 | 557486 | 1527239 | 64 | 504295 | 1555767 | 97 | 479513 | 1594787 |
| 32 | 556472 | 1529161 | 65 | 505850 | 1556478 | 98 | 482526 | 1591741 |
| 33 | 557749 | 1531827 | 66 | 507537 | 1556561 | | | |